**សហព័ន្ធខ្មែរកម្ពុជាក្រោម**
KHMER KAMPUCHEA-KROM FEDERATION
ASIA – AUSTRALIA – EUROPE – NORTH AMERICA A MEMBER OF UNPO - IDB
KKF P.O. Box 0193 • Pennsauken • NJ 08110 • Tel: (856) 655-9254 • Fax: (856) 583-1503
http://www.khmerkrom.org E-mail: thach.thach@khmerkrom.org

# សេចក្តីអំពាវនាវ

## ធ្វើមហាបាតុកម្មប្រវត្តិសាស្រ្ត នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៩
## ដើម្បីការពារសិទ្ធិមនុស្សខ្មែរនៅកម្ពុជាក្រោម

នៅមុខក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនាទីក្រុងហ្សឺណែវ ប្រទេសស្វិស

ប្រវត្តិសាស្រ្តខ្មែរនិងយួន បានបន្តភាពតានតឹងពីទសវត្សរ៍មួយទៅទសវត្សរ៍មួយ រហូតដល់ប្រវត្តិសាស្រ្តពិភពលោក បានបំភ្លេចចោលជនជាតិដើមទាំងឡាយ ជាង៣៧០លាននាក់ដោយសារសង្រ្គាមត្រជាក់ ឬសង្រ្គាមប្រល័យពូជសាសន៍តាមបែបសង្រ្គាមអាណានិគមនិយមថ្មី។ ករណីនេះ មេដឹកនាំយួនបានគេចផុតពីគំនាបពិភពលោក និងនៅតែបន្តការលំលោភជិះជាន់លើជនរួមឈាមខ្មែរនៅកម្ពុជាក្រោម។

បាតុកម្មជាវិធីមួយដើម្បីបង្ហាញនិងបញ្ចេញសម្លេងធ្វើគំនាបលើរដ្ឋាភិបាលកុម្មុយនិស្តក្រុងហាណូយដែលបន្តការរំលោភសិទ្ធិមនុស្សខ្មែរក្រោម ទោះបីជារដ្ឋកុម្មុយនិស្តនេះបានចុះហត្ថលេខាលើកតិកាសញ្ញាស្តីពីសិទ្ធិមនុស្សក៏ដោយនោះ។ មហាបាតុកម្មជាប្រវត្តិសាស្រ្ត នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៩ នៅមុខការិយាល័យក្រុមប្រឹក្សាសិទ្ធិមនុស្ស នាទីក្រុងហ្សឺណែវ ប្រទេសស្វិស ជាវេទិកាមួយ ដើម្បីបង្ហាញឲ្យពិភពលោកឃើញថា ខ្មែរក្រោមត្រូវបានគេបំភ្លេចចោល ដោយសារសង្រ្គាមរ៉ាំរ៉ៃ ដែលបង្ករឡើងដោយមេដឹកនាំយួនក្នុងបំណងតែមួយគត់គឺ យកទឹកដីកម្ពុជាក្រោមប៉ុណ្ណោះ។

**ខ្មែរក្រោមត្រូវតែក្រោកដើម្បីការពារសិទ្ធិរបស់ខ្លួន!!!**

ទង្វើរំលោភសិទ្ធិមនុស្ស នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, សេចក្តីប្រកាសសិទ្ធិជនជាតិដើម ត្រូវបានរំលោភដូចជា សិទ្ធិជំនឿសាសនា, សិទ្ធិស្រ្តី, សិទ្ធិបញ្ចេញមតិ, ជាពិសេសគឺសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង។

សហព័ន្ធខ្មែរកម្ពុជាក្រោម បានសម្រេចប្រកាសជាសាធារណៈថា និងបន្តបំភ្លឺនូវរាល់អំពើរំលោភសិទ្ធិមនុស្សនិងថ្កោលទោស ចំពោះស្ថានភាពបច្ចុប្បន្ន ដែលរដ្ឋាភិបាលនេះ បានប្រព្រឹត្តដោយអយុត្តិធម៌ខុសនិងសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិ, ខុសនិងសេចក្តីប្រកាសសិទ្ធិជនជាតិដើមនិងធម្មនុញ្ញក្រុងហានូយស្តីពីសិទ្ធិនៃជនជាតិនិមួយៗ។

ដើម្បីឱ្យមហាបាតុកម្មជាប្រវត្តិសាស្ត្រនិងទទួលបានជោគជ័យ,មានប្រសិទ្ធិភាពលើវេទិកាអន្តរជាតិដូចឆ្នាំ២០០៧នោះបាន គឺអាស្រ័យការគាំទ្រទាំងស្រុង ចំពោះជនរួមឈាមខ្មែរនៅទ្វីបអ៊ឺរ៉ុប មានកម្លាំងស្មារតី, កម្លាំងថវិកា, កម្លាំងកាយ។ ដោយឡែកគឺអាស្រ័យលើកម្លាំងខ្មែរទូទាំងសកលលោក សូមមេត្តាជួយជ្រោមជ្រែងដល់មហាបាតុកម្មនេះដូចមាន៖ ធ្វើជាលិខិតគាំទ្រ, ថវិកាជួយដល់ក្រុមបាតុករ, ជួយបន្តការផ្សព្វផ្សាយដល់ជនរួមឈាមខ្មែរ ជាញាតិមិត្ត, និងកូនចៅ, ព្រមទាំងសូមមេត្តាជំរាបដល់មិត្តភ័ក្រជនបរទេស, អង្គការក្រៅរដ្ឋាភិបាល, មន្ត្រីរដ្ឋាភិបាល និងរដ្ឋាភិបាលក្នុងប្រទេសដែលជនរួមឈាមខ្មែរយើងរស់នៅ។

មហាបាតុកម្មអហឹង្សា ជាប្រវត្តិសាស្ត្រនិងជាលើកទី១ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កោះហៅរដ្ឋាភិបាលយួនកុម្មុយនិស្ត មកបំភ្លឺចំពោះមុខអន្តរជាតិនូវការរំលោភសិទ្ធិម្ចាស់ស្រុក។

សូមមេត្តាផ្ញើវិភាគទាន បេសកកម្មសិទ្ធិមនុស្សក្រុងស្សឺណែវ ទៅកាន់អាស័យដ្ឋានដូចខាងក្រោម៖

-លោក ថាច់ វៀន នៅប្រទេសបារាំង Email: t-vien@club-internet.fr

- FKKE, BP 69, 93423 – Villepinte, Cedex. France. Tel: +336 2561 1961 – Siret: 441-892-080-00017

-អាមេរិក៖ **KKF P.O. Box 0193 Pennsauken. NJ 08110 Tel: (856) 655-9254 Fax: (856) 583-1503**

-អូស្ត្រាលី៖ 53/55 Balmoral Ave. Springvale Victoria 3171 Australia Tel: 61395403374

-ញូវស្សឺឡែន៖ 36 Hain Ave. Mangere East. Auckland 1701 New Zealand Tel: **64 9276 5752**

-កាណាដា៖ **P.O. Box 39084 London ON N5Y5L1 CANADA. Tel/Fax: (519) 659-3920**

-ព័ត៌មានបន្ថែម សូមលោកអ្នកទំនាក់ទំនងសកម្មជនសហព័ន្ធតាមតំបន់ដែលលោកអ្នករស់នៅ។

សូមព្រះតេជគុណ លោក លោកស្រីមេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់!

សូមអរព្រះគុណនិងសូមអរគុណ!

ធ្វើនៅសហរដ្ឋអាមេរិក, ថ្ងៃទី១០មីនា ឆ្នាំ២០០៩

អំពីខ្ញុំព្រះករុណាខ្ញុំបាទ

ថាច់ ង៉ុក ថាច់

ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម